# ព្រះរាជក្រម

នស/រកម/០២១១/០០៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឲ្យប្រើ

ច្បាប់កែតម្រូវ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

# ច្បាប់កែតម្រូវ

# ស្តីពី

# ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០

**មាត្រា ១.-**

ត្រូវបានយល់ព្រមជាគោលការណ៍ ក្នុងក្របខ័ណ្ឌច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ឲ្យខ្ចីប្រាក់ពីគេបន្ថែមដូចខាងក្រោម :

- យល់ព្រមឲ្យរាជរដ្ឋាភិបាលខ្ចីប្រាក់ពីគេបន្ថែមទៀត មានកម្រិតរហូតដល់ ៣០.០០០.០០០ SDR ( សាមសិបលានអេសដេអ៊ែ ) សម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ។
- យល់ព្រមឲ្យរាជរដ្ឋាភិបាលខ្ចីប្រាក់ពីគេបន្ថែម មានកម្រិតរហូតដល់ ១៧០.០០០.០០០ SDR ( មួយរយចិតសិបលានអេសដេអ៊ែ ) សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ។

**មាត្រា ២.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ ២០១១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣រល.១១០២.១៣៩

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**

លេខៈ១៣៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ កុម្ភៈ ឆ្នាំ២០១១

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

[illegible] ជិនកេន